# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទកំពង់ត្រឡាច

សម្រាប់រយៈពេល៣ឆ្នាំ (ខែកក្កដា ឆ្នាំ២០២៤ ដល់ ខែមិថុនា ឆ្នាំ២០២៧)

| | |
|---|---|
| សហគមន៍នេសាទ | ៖ កំពង់ត្រឡាច |
| ភូមិ | ៖ កំពង់ត្រឡាច |
| សង្កាត់ | ៖ ព្រៃធំ |
| ក្រុង | ៖ កែប |
| ខេត្ត | ៖ កែប |

# មាតិកា


**១.ស្ថានភាពទូទៅ** ........................................ ១

**២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ........................................ ១

ក.ប្រជាពលរដ្ឋ ........................................ ១

ខ.មុខរបរ ........................................ ២

**៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងសហគមន៍នេសាទ** ........................................ ២

ក.ទីតាំង ........................................ ២

ខ.ដែននេសាទ ........................................ ២

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........................................ ២

ឃ.ធនធានជលផល ........................................ ៣

ឃ.១.ប្រភេទត្រី ........................................ ៣

ឃ.២.ប្រភេទវារីសត្វ ........................................ ៣

ឃ.៣.ប្រភេទបក្សី ........................................ ៣

ឃ.៤.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ ........................................ ៣

**៤.ការធ្វើនេសាទ** ........................................ ៣

ក.អ្នកនេសាទ ........................................ ៣

ខ.ឧបករណ៍នេសាទ ........................................ ៣

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........................................ ៤

**៥.ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ** ........................................ ៥

ក.ទស្សនៈវិស័យ ........................................ ៥

ខ.គោលបំណង ........................................ ៥

គ.ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ ........................................ ៥

គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........................................ ៥

គ.២.ផែនការចុះល្បាត ........................................ ៥

គ.៣.ផែនការកែលំអរដែននេសាទ ........................................ ៦

គ.៤.ផែនការរៀបចំកន្លែងអភិរក្ស ........................................ ៦

គ.៥.ផែនការគ្រប់គ្រងព្រៃកោងកាង ........................................ ៧

គ.៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........................................ ៨

គ.៧.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព ........................................ ៨

គ.៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តសហគមន៍នេសាទ ........................................ ៩

គ.៩.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........................................ ១០

*គ.១០.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ................................១១*
គ.១១.ផែនការបំពាក់សម្ភារៈសហគមន៍នេសាទ..........................................................................១១
គ.១២.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍..........................................................១២
គ.១៣.ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ.....................................................................១២
**ឃ.យុទ្ធសាស្ត្រ** .......................................................................................................................១២

## ៦.ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទឆ្នាំ២០២៤-២០២៧.............................១៤
តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទក្នុងរយៈពេល០៣ឆ្នាំ២០២៤-២០២៧................១៩

# ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទកំពង់ត្រឡាច

## ១- ស្ថានភាពទូទៅ

នៅឆ្នាំ២០០០រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឱ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែលជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្ដោតលើការកាត់បន្ថយភាពក្រីក្រដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាពនិងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍និងធ្វើឱ្យធនធានជលផលប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ កន្លងមកភូមិកំពង់ត្រឡាច ត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានទទួលការគាំទ្រថវិកាពីរដ្ឋបាលជលផល និងមានកិច្ចសហការពីអាជ្ញាធរដែនដី។ ដូចនេះ សហគមន៍នេសាទកំពង់ត្រឡាច ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១០ ព្រមទាំងត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួលស្គាល់នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ ដែលបានរៀបចំផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទកន្លងមក។ លើកទី១ ត្រូវបានរៀបចំ និងអនុវត្តចាប់ពីឆ្នាំ២០១២ ដល់២០១៤ ហើយបានធ្វើបច្ចុប្បន្នភាពសម្រាប់អនុវត្តចាប់ពីខែមិថុនា ឆ្នាំ២០២៤ ដល់ ខែឧសភា ឆ្នាំ២០២៧។

គណៈកម្មការសហគមន៍នេសាទត្រូវបានបោះឆ្នោតដែលមានចំនួន០៩នាក់ ក្នុងនោះស្ត្រីមានចំនួន២នាក់ ដោយមានសមាជិកសរុបចំនួន២១០នាក់ ក្នុងស្ត្រីចំនួន៧៥នាក់ ព្រមទាំងបានអនុវត្តភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងសហគមន៍នេសាទ និងកិច្ចព្រមព្រៀងកន្លែងនេសាទ។ ទន្ទឹមនឹងនេះ គណៈកម្មការសហគមន៍នេសាទ ត្រូវបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំបណ្តាញ ការងារទស្សនៈកិច្ចសិក្សានិងរៀនសូត្រតាមឯកសារផ្សេងៗ។

ដូច្នេះ ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទកំពង់ត្រឡាច បានធ្វើការកែសម្រួលសកម្មភាពសំខាន់ៗ និងថវិកាដែលគ្រោង ដើម្បីអាចធានាដល់ការគ្រប់គ្រងធនធានជលផលនៅក្នុងកន្លែងអភិរក្សសហគមន៍នេសាទ និងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីធនធានជលផលប្រកបដោយនិរន្តរភាព និងសមធម៌។

## ២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ពេលបច្ចុប្បន្ន សង្កាត់ព្រៃធំមានចំនួន០៣ភូមិគឺ ភូមិកំពង់ត្រឡាច ភូមិថ្មី និងភូមិដំណាក់ចង្អើរ ដោយឡែកសហគមន៍នេសាទកំពង់ត្រឡាច គ្របដណ្តប់តែមួយភូមិគឺ ភូមិកំពង់ត្រឡាចដែលមានប្រជាពលរដ្ឋសរុបចំនួន៥៧០គ្រួសារ ហើយគ្រួសារដែលមាន ស្ត្រីជាមេគ្រួសារមានចំនួន១០៧គ្រួសារ។

សហគមន៍នេសាទកំពង់ត្រឡាច មានស្ថានភាពដូចជា៖

- ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅក្នុងសហគមន៍នេសាទកំពង់ត្រឡាច បានបង្ហាញថា នៅភូមិកំពង់ត្រឡាច មានគ្រួសារក្រីក្រ-១មានចំនួន១៤គ្រួសារ និងក្រីក្រ-២មានចំនួន៥៤គ្រួសារ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន៨៦នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមានចំនួន០៧នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានចំនួន១២នាក់ ក្នុងនោះស្ត្រីមានចំនួន៨នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន៣៥នាក់ ក្នុងនោះស្ត្រីមានចំនួន១៨នាក់
- ចំនួនអ្នកមានជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន០៥នាក់
- តាមរបាយការណ៍របស់សង្កាត់ នៅក្នុងសហគមន៍នេសាទនេះ មានចំនួន១២នាក់ ដែលមិនចេះអក្សរ។

ខ.មុខរបរ

តាមរបាយការណ៍ និងឯកសារព័ត៌មានសង្កាត់ឆ្នាំ២០២៤ បានបញ្ជាក់ថា នៅក្នុងសហគមន៍នេសាទកំពង់ត្រឡាច មានប្រជាពលរដ្ឋសរុបចំនួន៥៧០គ្រួសារ ក្នុងនោះស្ត្រីដែលជាមេគ្រួសារមានចំនួន១០៧គ្រួសារ ដែលមួយចំនួនពឹងផ្អែកលើ ការធ្វើស្រែ ការធ្វើនេសាទ ការចិញ្ចឹមសត្វ កម្មករ និងលក់ដូរ។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមក រដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីការចិញ្ចឹមត្រីលក្ខណៈគ្រួសារ បច្ចេកទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមជីវិតផ្សេងៗទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន ។

ពេលបច្ចុប្បន្ន សហគមន៍នេសាទកំពង់ត្រឡាច មានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗរួមមានៈ

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | កំណត់សំគាល់ |
|---|---|---|---|
| ១ | អ្នកដែលមានមុខរបរពឹងផ្អែកលើការនេសាទ | ១៨៥ | |
| ២ | អ្នកធ្វើស្រែ | ២៨៨ | |
| ៣ | អ្នកចិញ្ចឹមសត្វ(គោ ក្របី មាន់និងទា) | ៥១៣ | |
| ៤ | អ្នកដាំបន្លែ | ៧២ | |
| ៥ | អ្នកលក់ដូរ | ១៥ | |
| ៦ | ជាងផ្ទះ | ០២ | |
| ៧ | កម្មករ | ៩៥ | |
| ៣ | អ្នកលកដូរវត្ថុអនុស្សាវរីយ៍ | ០១ | |

## ៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងសហគមន៍នេសាទ

ក.ទីតាំង

សហគមន៍នេសាទកំពង់ត្រឡាច មានទីតាំងស្ថិតក្នុងភូមិកំពង់ត្រឡាចដែលជាដែននេសាទសាធារណៈរបស់រដ្ឋ ហើយដែននេសាទនៅជាប់សមុទ្រដែលស្ថិតក្នុងសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។ សហគមន៍នេសាទកំពង់ត្រឡាចត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣។

ដូចនេះ សហគមន៍នេសាទកំពង់ត្រឡាច មានព្រំប្រទល់ជាប់នឹងៈ

- ខាងជើងទល់នឹងសហគមន៍នេសាទអូរក្រសារ
- ខាងត្បូងទល់នឹងសហគមន៍នេសាទភូមិថ្មី
- ខាងកើតទល់នឹងស្រែអំបិល
- ខាងលិចទល់នឹងសមុទ្រ។

ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទកំពង់ត្រឡាច មានវិសាលភាពនៅលើដែននេសាទសមុទ្រដែលមានកន្លែងសហគមន៍នេសាទមានទំហំ៤២២ហិកតា ហើយមានដែននេសាទតំបន់ឆ្នេរ។

**ឃ.ធនធានជលផល**

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីសហគមន៍នេសាទកំពង់ត្រឡាចបានឱ្យដឹងថា ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសមុទ្រមិនមានការកើនឡើងទេដោយសារមានការប្រែប្រួលអាកាសធាតុ។ ក្រុមការងារ និងសមាជិកសហគមន៍បានអង្កេតឃើញថា ធនធានជលផលក្នុងសហគមន៍នេសាទនេះមានដូចជា៖

**ឃ.១.ប្រភេទត្រីសមុទ្រ:**

ក្នុងសហគមន៍នេសាទកំពង់ត្រឡាចមានប្រភេទត្រីដូចជា៖ ត្រីឆ្កង់ ត្រីក្បក ត្រីប្រកុង ត្រីអាំងកឺយ ត្រីចង្កោមបី ត្រីដំឡូង ត្រីប្លាធូ ត្រីកូចិន ត្រីស្លុងក្រហម ត្រីថ្កេង ត្រីក្រសក់ ត្រីឆ្លាម ត្រីការ៉ាវ ត្រីប្រម៉ា ត្រីកិ ត្រីកន្ទុង ត្រីកាម៉ុង ត្រីក្បាលឡាន ត្រីអណ្តែងប៉ុយ ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីកាបាស ត្រីបបែល ត្រីឆ្លាត ត្រីក្អុក ត្រីបាលង្គ ត្រីកាឡាំង ត្រីអង្រែ ត្រីគូន ត្រីសេក ត្រីតុកកែ ត្រីផ្ទក់សមុទ្រ ត្រីសេះ។ល។

**ឃ.២.ប្រភេទវារីសត្វសមុទ្រ:**

ក្នុងសហគមន៍នេសាទនេះ មានប្រភេទវារីសត្វដូចជា៖ បង្កង បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ មឹក គ្រែងឈាម ងាវភក់ ហូល ងាវស បង្កងប៉ាក អណ្តើក កន្ធាយ បាលង្កាស កញ្ជា អន្ទង់ ខ្ញីង។ល។

**ឃ.៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ**

ក្នុងសហគមន៍នេសាទកំពង់ត្រឡាច មានប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិដូចជា៖ ផ្កាថ្ម ស្មៅសមុទ្រ និងតំបន់ព្រៃកោកាង។ល។

## ៤-ការធ្វើនេសាទ

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាសង្កាត់ ភូមិ និងសហគមន៍នេសាទកំពង់ត្រឡាចបានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងសហគមន៍នេសាទកំពង់ត្រឡាចមានដូចខាងក្រោម៖

**៤.ក.អ្នកនេសាទ**

ពេលបច្ចុប្បន្ន សហគមន៍នេសាទកំពង់ត្រឡាចមានអ្នកនេសាទចំនួន៤៨៥នាក់ក្នុងនោះស្ត្រីចំនួន៩៤នាក់។ ក្នុងដំណើរការគ្រប់គ្រងសហគមន៍នេសាទ ប្រជាពលរដ្ឋខ្លះបានចុះឈ្មោះចូលជាសមាជិកសហគមន៍នេសាទ ប៉ុន្តែ ប្រជាពលរដ្ឋខ្លះទៀតពុំទាន់បានចុះឈ្មោះជាសមាជិកសហគមន៍នេសាទនៅឡើយទេ។ អ្នកនេសាទក្នុងសហគមន៍នេះមានដូចជា៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន២១០នាក់ ក្នុងនោះស្ត្រីមានចំនួន៧៥នាក់។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នៅក្នុងសហគមន៍នេសាទចំនួន៦៤នាក់ក្នុងនោះស្ត្រីចំនួន១៩នាក់
- តាមការប៉ាន់ស្មានអ្នកនេសាទមកពីខាងក្រៅដែលមិនមែនជាសមាជិកសហគមន៍ចំនួន២១០នាក់ក្នុង១ឆ្នាំ។

**៤.ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍មានដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ចំនួនគ្រួសារ | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ១ | មងត្រី | ម៉ែត្រ | ៤០ | ៣,៥សម x ៥០០ម | ពេញមួយឆ្នាំ |
| ២ | លបក្តាម | លប | ១៥ | ២០០ | ពេញមួយឆ្នាំ |
| ៣ | មងបង្គា | ម៉ែត្រ | ២៥ | ៣,៨សម x ៥០០ម | ពីខែ៥ ដល់ ខែ៩ |
| ៤ | សន្ទូចរនង | ផ្លែ | ១២ | ៥០០ | ពីខែ៤ ដល់ ខែ១១ |
| ៥ | សន្ទូចមឹក | ខ្សែ | ៥០ | ១០០០ផ្លែ | ពីខែ១១ ដល់ ខែ៤ |
| ៦ | លបត្រី | លប | ១២ | ១៥លប | ពីខែ៦ ដល់ ខែ៩ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកម៉ាស៊ីន | ៤៥ | ៧០០-១០០០ | ៦ ដល់ ១៣ |
| ២ | ទូកចែវ | ០៥ | ៧០-១០០ | |

**ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកខាងក្នុងសហគមន៍នេសាទតែមិនមែនជាសមាជិក**

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ចំនួនគ្រួសារ | ប្រវែង/ទំហំ/គ្រួសារ | រដូវនេសាទ |
|---|---|---|---|---|---|
| ១ | មងត្រី | ម៉ែត្រ | ២០ | ៤ដៃ(១ដៃ=៦០ម) | ពេញមួយឆ្នាំ |
| ២ | លបក្តាម | លប | ១៥ | ៥០០-១០០០ | ពេញមួយឆ្នាំ |
| ៣ | មងបង្គា | ម៉ែត្រ | ១៥ | ៤ដៃ(១ដៃ=៦០ម) | ពីខែ៥ ដល់ ខែ៩ |
| ៤ | រនងខ្យង | ផ្លែ | ០២ | ២០០០ | ពីខែ៤ ដល់ ខែ៩ |
| ៥ | សន្ទូចមឹក | ខ្សែ | ៣០ | ២ខ្សែ=១២ផ្លែ | ពីខែ១១ ដល់ ខែ៤ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកម៉ាស៊ីន | ៣០ | ៤០០ | ៦ ដល់ ១៣ |
| ២ | ទូកចែវ | ០៥ | ៧០-១០០ | |

**ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ**

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ចំនួននាក់ | ប្រវែង/ទំហំ |
|---|---|---|---|---|
| ១ | មងក្តាម | ម៉ែត្រ | ១៥ | ៥០០ម/១នាក់ |
| ២ | លបក្តាម | លប | ២២ | ៣០០-៥០០លប/១នាក់ |
| ៣ | លបត្រី | ម៉ែត្រ | ០៥ | ២០-៣០លប/១នាក់ |
| ៤ | លូកក្តាមថ្ម ក្តាមជ័រ | នាក់ | ១៥ | |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ៣៥ | ៤០០ | ៦ ដល់ ១៣ |

**គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ**

តាមការអង្កេត និងការសិក្សាស្រាវជ្រាវរបស់ក្រុមការងាររដ្ឋបាលជលផលថ្នាក់កណ្តាល និងមន្ត្រីខណ្ឌរដ្ឋបាលជលផលកែបដោយរួមសហការជាមួយគណៈកម្មការសហគមន៍នេសាទបានបង្ហាញ សមាជិកសហគមន៍នេសាទបានប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារដូចរៀបរាប់ខាងលើ ដើម្បីធ្វើនេសាទនៅកន្លែងសហគមន៍នេសាទក្នុងរដូវវស្សា និងរដូវប្រាំង។ ពេលបច្ចុប្បន្ន សហគមន៍នេសាទកំពង់ត្រឡាច មានអ្នកនេសាទចំនួន៤៨៥នាក់ក្នុងនោះស្ត្រីចំនួន៩៤នាក់ហើយក្រុមការងារបានជ្រើសរើសសំណាកអ្នកនេសាទក្នុងដែនសហគមន៍នេសាទចំនួន១៣នាក់ មកធ្វើការប៉ាន់ប្រមាណផលនេសាទចាប់បានដែលគិតជាមធ្យមប្រចាំឆ្នាំ។ ការជ្រើសរើសសំណាក ត្រូវធ្វើឡើងដោយផ្អែកលើអ្នកនេសាទដែលជាសមាជិកសហគមន៍ អ្នកនេសាទមិនមែនជាសមាជិកសហគមន៍ និងការប៉ាន់ប្រមាណអ្នកនេសាទមកពីខាងក្រៅ ហើយការប៉ាន់ប្រមាណផលនេសាទចាប់បានដែលគិតជាមធ្យមប្រចាំឆ្នាំ២០២៤ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គក្រ) | | |
|---|---|---|---|---|
| | | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ១ | ត្រីគ្រប់ប្រភេទ | ១៥៧៩ | ១៣៤៥ | ២៩២៤ |
| ២ | បង្គា | ១១៣៤ | ១០២១ | ២១៥៥ |
| ៣ | ក្ដាម | ៩១៣ | ៨០៥ | ១៧១៨ |
| ៤ | មឹក ខ្យង និងគ្រែងឈាម | ៧៦៨ | ៥៧៩ | ១៣៤៧ |
| សរុប | | ៤៣៩៤ | ៣៧៥០ | ៨១៤៤ |

**៥. ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ**

**ក.ទស្សនៈវិស័យ**

សហគមន៍នេសាទកំពង់ត្រឡាច មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**ខ.គោលបំណង**

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីក្នុងរដូវទឹកជោរ ព្រៃកោងកាង និងការគ្រប់គ្រងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះ
- ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

**គ.ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ**

**គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទៈ**

**គោលបំណង**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទកំពង់ត្រឡាចគឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ និងរដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

**ទីតាំង ឬកន្លែងនេសាទ**

| ល.រ | ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | |
|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង |
| ១ | ដែននេសាទផ្សេងៗក្រៅពីតំបន់អភិរក្ស | ពេញមួយឆ្នាំ | មងបង្គា មងត្រី លបក្ដាម ឈិបរុញ សន្ទូចមឹក រនងខ្យង ឈ្នាង | ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលេខ ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ខែមិថុនា ឆ្នាំ២០១៥។ |

### គ.២.ផែនការចុះល្បាត

ជាទូទៅ ការចុះល្បាតជាភារកិច្ចរបស់គណៈកម្មការ និងសមាជិកសហគមន៍ ប៉ុន្តែ ការចុះល្បាតនេះគឺផ្អែកលើការជួយឧត្ថម្ភពីដៃគូអភិវឌ្ឍន៍។ កន្លងមក ការចុះល្បាតលើកន្លែងសហគមន៍នេសាទបានអនុវត្តតិចតួច ពីព្រោះថា ខ្វះមធ្យោបាយល្បាត ដូចនេះ សហគមន៍នេសាទកំពង់ត្រឡាចបានរៀបចំផែនការល្បាត ក្នុងគោលបំណង៖

- ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់
- សមាជិកអាចទទួលបានផលនេសាទពីកន្លែងសហគមន៍នេសាទ
- គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព

ផែនការចុះល្បាត ដើម្បីទប់ស្កាត់បទល្មើសជលផលត្រូវបានរៀបចំដូចខាងក្រោម៖

| លរ | សកម្មភាព | អ្នកចូលរួម | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ១ | ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០០ ០០០ | ២០២៤ | ២០២៧ |
| ២ | រៀបចំមធ្យោបាយ និងសម្ភារៈ<br>-សាំង និងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក កាល្បត<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយិត | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | ២ ០០០ ០០០ | ២០២៤ | ២០២៧ |
| ៣ | ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ជំនាញជលផល អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ | ១០០ ០០០ | ២០២៤ | ២០២៤ |
| ៤ | អនុវត្តផែនការ និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ជលផលនិងជំនាញពាក់ព័ន្ធ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ៥ ០០០ ០០០ | ២០២៤ | ២០២៧ |

### គ.៣.ផែនការកែលំអរដែននេសាទ

ផែនការកែលំអដែននេសាទគឺ ជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស និងថវិកាប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថា ការកែលំអដែននេសាទសហគមន៍នេះ វាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូចនេះ កិច្ចប្រជុំរវាងគណៈកម្មការ និងសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាលបានពិនិត្យឃើញថា ដែននេសាទនៅក្នុងសហគមន៍នេសាទកំពង់ត្រឡាចមានសភាពប្រែប្រួលខ្លះដែលបណ្តាលមកពីកត្តាមនុស្ស និងធម្មជាតិ។

ផែនការកែលំអដែននេសាទក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ
- ធ្វើឱ្យសំបូរព្រៃកោងកាងឱ្យនៅក្នុងដែននេសាទសហគមន៍
- ទាក់ទាញភ្ញៀវទេសចរណ៍។

ផែនការកែលំអដែននេសាទ នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះដែននេសាទ | ទំហំ (ហត) | ទំហំដែលត្រូវកែលំអរ | សកម្មភាព | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|---|
| | | | | | | ចាប់ផ្តើម | បញ្ចប់ |
| ១ | ព្រំប្រទល់ព្រែកនង្គល | ៤០០០ម | ២០០០មx ខ្នង២០ម បាតក្រោម ១២ម កំពស់ ៣ម | ស្តារព្រែក | ២៥ ០០០ ០០០ | ២០២៤ | ២០២៧ |

## គ.៤.ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទកំពង់ត្រឡាច នឹងបង្កើតកន្លែងអភិរក្សកន្លែងដែលត្រូវធ្វើការគ្រប់គ្រងដោយគណៈកម្មការ និងសមាជិកសហគមន៍នេសាទកំពង់ត្រឡាច ក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃកោងកាងដែលជាជម្រក និងប្រភពចំណីរបស់ត្រី និងវារីសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋឱ្យចេះស្រឡាញ់ថែរក្សា និងការពារធនធានធម្មជាតិ
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេតរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការនិងសមាជិកសហគមន៍នេសាទនេះបានបញ្ជាក់ថា សហគមន៍នេសាទកំពង់ត្រឡាចនឹងបង្កើតកន្លែងអភិរក្សដែលពុំអនុញ្ញាតិទូកនេសាទ ឬកាណូតធ្វើការឆ្លងកាត់ក្នុងកន្លែងអភិរក្សនេះដែលជាកន្លែងសំខាន់បំផុត សម្រាប់ធ្វើការអភិរក្សធនធានជលផលដែលសមាជិកសហគមន៍នេសាទមានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់សមាជិកសហគមន៍។ កន្លែងអភិរក្សនេះ ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្តាខៀនព័ត៌មាន បិទផ្សាយបទបញ្ញតិផ្សេងៗសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយ និងសម្ភារៈ។ ដូចនេះផងដែរ សហគមន៍នេសាទកំពង់ត្រឡាច នឹងកំណត់កន្លែងអភិរក្សដូចបានបញ្ជាក់ក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ឯកតា | បរិមាណ | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| ១ | ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | លើក | ២ | ២៣ ០០០ ០០០ | ២០២៤ | ២០២៧ |
| ២ | កំណត់និយាមកានៃទីតាំង | លើក | ៣ | | | |
| ៣ | បោះបង្គោលព្រំប្រទល់ | ដើម | ២០ | | | |
| ៤ | បោះបង្គោលកន្លែងអភិរក្ស | ដើម | ១០ | | | |
| ៥ | ធ្វើស្លាកសញ្ញាតូច | ស្លាក | ៦០ | | | |
| ៦ | ធ្វើផ្ទាំងប៉ាណូ | ស្លាក | ០៤ | | | |
| ៧ | សង់រោងយាម | ប៉ុស្តិ៍ | ១ | | | |
| ៨ | តាមដាន និងត្រួតពិនិត្យ | លើក | ១៥ | | | |

### គ.៥.ផែនការគ្រប់គ្រងព្រៃកោងកាង

ព្រៃកោងកាងបានគ្របដណ្តប់លើដែននេសាទសហគមន៍ដែលបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រីសត្វល្អូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀតសម្រាប់ជាជម្រករស់នៅបង្កកំណើតជាកូន និងជាចំណីផងដែរ។ ដូចនេះ ផែនការគ្រប់គ្រងព្រៃកោងកាង ក្នុងគោលបំណងដូចជា៖

- ថែរក្សា ការពារព្រៃកោងកាងឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី វារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឱ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទបានកំណត់ និងបែងចែកព្រៃកោងកាង កន្លែងអភិរក្ស និងកន្លែងប្រើប្រាស់ព្រៃកោងកាងដោយផ្អែកតាមផែនទីសហគមន៍នេសាទ។ កន្លែងប្រើប្រាស់ព្រៃកោងកាង ត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យចេះកាប់រំលោះមែកដែលធ្វើយ៉ាងណាមិនឱ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារជាពិសេស ដោយសារការយល់ដឹងពីសារៈសំខាន់នៃព្រៃកោងកាង ប្រជាពលរដ្ឋមានការចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង។

ផែនការគ្រប់គ្រងព្រៃកោងកាង ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះ/ទីតាំង | ទំហំ ហត | ប្រភេទកូនឈើ ដែលត្រូវការពារ | សកម្មភាព | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|---|
| | | | | | | ចាប់ផ្តើម | បញ្ចប់ |
| ១ | ដាំកូនព្រៃកោងកាង | ៣ | ព្រៃកោងកាង | • ផ្សព្វផ្សាយ<br>• បោះបង្គោល<br>• ដាក់ស្លាកសញ្ញា<br>• ត្រួតពិនិត្យ | ៤ ០០០ ០០០ | ២០២៤ | ២០២៧ |
| ២ | ថែរក្សា និងការពារព្រៃកោកាង | ៦៦ | ព្រៃកោងកាង | ចុះល្បាត | ១ ០០០ ០០០ | ២០២៤ | ២០២៧ |

### គ.៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសលេខ៣២៥ប្រក កសកស្តីពីការគ្រប់គ្រងការចិញ្ចឹមត្រីរស់ ត្រីឆ្ពោរដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ កន្លងមក សមាជិកសហគមន៍នេសាទកំពង់ត្រឡាចបានចិញ្ចឹមត្រីសមុទ្រខ្លះ។ ដូចនេះ ដើម្បីឆ្លើយតបនឹងតម្រូវការ សហគមន៍នេសាទកំពង់ត្រឡាចមានផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រីឆ្តុង ត្រីតុកកែ ក្តាមថ្ម និងក្តាមសេះ ក្នុងគោលបំណង៖

- បង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទបានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រី និងក្តាមដូចខាងក្រោម៖

| ល.រ | ប្រភេទវារីវប្បកម្ម | សកម្មភាព | ប្រភេទពូជ | បរិមាណពូជ | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|---|
| | | | | | | ចាប់ផ្តើម | ប្រមូលផល |
| ១ | ចិញ្ចឹមត្រីឆ្តុងលក្ខណៈគ្រួសារក្នុងបែចំនួន ២០គ្រួសារ(៥មx ៣មx ២,៥ម) | • ជ្រើសរើសស.ន<br>• បណ្តុះបណ្តាល<br>• ធ្វើបែចិញ្ចឹម<br>• ផ្តល់ពូជ | កូនត្រីឆ្តុង | ៥០០ /គ្រួសារ | ៥ ០០០០០០ | ២០២៤ | ២០២៧ |
| ២ | ចិញ្ចឹមត្រីឆ្តុកកែលក្ខណៈគ្រួសារ ចំនួន៦គ្រួសារក្នុងបែ (៥មx៣ម x២,៥ម) | • ជ្រើសរើសស.ន<br>• បណ្តុះបណ្តាល<br>• ធ្វើកន្លែងចិញ្ចឹម<br>• ផ្តល់កូន | ត្រីឆ្តុកកែ | ៥០០ កូន/ គ្រួសារ | ៧០០០ ០០០ | ២០២៤ | ២០២៧ |
| ៣ | ចិញ្ចឹមអយស្ទ័រឬគ្រុំចំពុះទាចំនួន ១០គ្រួសារ | • ជ្រើសរើសស.ន<br>• បណ្តុះបណ្តាល<br>• ធ្វើកន្លែងចិញ្ចឹម<br>• ផ្តល់កូន | អយស្ទ័រ ឬគ្រុំ ចំពុះទា | ១៥ កន្លែង/ គ្រួសារ | ៣០០០ ០០០ | ២០២៤ | ២០២៧ |
| ៤ | ចិញ្ចឹមក្តាមថ្មលក្ខណៈគ្រួសារចំនួន១០ គ្រួសារតាមបៀរ | • ជ្រើសរើសស.ន<br>• បណ្តុះបណ្តាល<br>• ធ្វើកន្លែងចិញ្ចឹម<br>• ផ្តល់កូន | ក្តាមថ្ម | ២៥០ ក្តាម/ គ្រួសារ | ៤០០០ ០០០ | ២០២៤ | ២០២៧ |
| ៥ | ធ្វើជាគារក្តាមសេះ ចំនួន១៥គ្រួសារ ក្នុងបែ | • ជ្រើសរើសស.ន<br>• បណ្តុះបណ្តាល<br>• សង់បែចិញ្ចឹម<br>• ផ្តល់មេក្តាម | ក្តាមសេះ | ១០០០ ក្បាល | ៤០០០ ០០០ | ២០២៤ | ២០២៧ |

**គ.៧.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព**

ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទកំពង់ត្រឡាច ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។កន្លងមក រដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍ បានជួយបណ្តុះបណ្តាលអំពីការចិញ្ចឹមត្រីលក្ខណៈគ្រួសារ និងបច្ចេកទេសការចិញ្ចឹមសត្វ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្នុងគោលបំណងដូចជា៖

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរ និងមានដើមទុនសម្រាប់បង្កើនប្រាក់ចំណូល
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទកំពង់ត្រឡាច មានផែនការអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតសហគមន៍ ដោយបានរៀបចំផែនការចិញ្ចឹមមាន់ ទា និងជ្រូក ព្រមទាំងការដាំដំណាំតាមបច្ចេកទេសលក្ខណៈគ្រួសារ។ ដូចនេះ ផែនការអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|---|
| | | | | | | ចាប់ផ្តើម | ប្រមូលផល |
| ១ | ការចិញ្ចឹមមាន់-ទា លក្ខណៈគ្រួសារ ចំនួន៧គ្រួសារ | • ជ្រើសរើសស.ន<br>• បណ្តុះបណ្តាល<br>• ផ្តល់ពូជ-សម្ភារៈ | មាន់ ទា សំពៅ | ១០ ក្បាល /គ្រួសារ | ៥០០ ០០០ | ២០២៤ | ២០២៧ |
| ២ | ការកែច្នៃផ្អក លក្ខណៈគ្រួសារ ចំនួន៥គ្រួសារ | • ជ្រើសរើសស.ន<br>• បណ្តុះបណ្តាល<br>• ផ្តល់ពូជ-សម្ភារៈ | ផ្អក | អាស្រ័យលើគ្រួសារ | ៥០០ ០០០ | ២០២៤ | ២០២៧ |
| ៣ | ការកែច្នៃគីលក្ខណៈ គ្រួសារចំនួន៥ គ្រួសារ | • ជ្រើសរើសស.ន<br>• បណ្តុះបណ្តាល<br>• ផ្តល់ពូជ-សម្ភារៈ | គី | អាស្រ័យលើគ្រួសារ | ៥០០ ០០០ | ២០២៤ | ២០២៧ |

**គ.៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ**

ពេលបច្ចុប្បន្ន សហគមន៍នេសាទកំពង់ត្រឡាច បានគ្រោងផែនការរៀបចំកន្លែងកំសាន្តនៅក្នុងដែននេសាទរបស់សហគមន៍នេសាទដែលអាចជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ និងកាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯងសម្រាប់ក្នុងការចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍កំពង់ត្រឡាច ក្នុងគោលបំណងដូចជា៖

- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ |
| រៀបចំកន្លែងកំសាន្ត សហគមន៍នេសាទ កំពង់ត្រឡាច | ផ្សព្វផ្សាយ<br>រៀបចំក្រុម<br>បង្កើតគោលការណ៍<br>បណ្តុះបណ្តាល<br>កញ្ចុះ និងផ្ទះលំហែ ផ្ទះបាយ បន្ទប់ទឹក<br>ជួសជុលផ្លូវ<br>សង់ស្ពាន និងចំណតយានយន្ត<br>បំពាក់សម្ភារៈ ភ្លើង និងទឹក<br>រៀបចំសួនថតអនុស្សាវរី<br>កន្លែងគ្រប់គ្រងកាកសំណល់ | ២៥ ០០០ ០០០ | ២០២៤ | ២០២៧ |

### គ.៩.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទត្រូវបានបញ្ជាក់ពីគុណភាព និងចំណេះដឹងដូចជា៖ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការ បានប្រើនិតិវិធីស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទដែលបានអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែង គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទគឺ ថ្មីដែលសមត្ថភាពរបស់សមាជិកគណៈកម្មការមាន កំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួលទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ដូចនេះ ផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទ នឹងត្រូវបានរៀបចំក្នុងគោលបំណង៖

- គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពការងារ
- យល់ពីតួនាទី និងភារកិច្ចរបស់ពួកគាត់
- បង្កើនសាមគ្គីភាព ការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ។

ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| លរ | សកម្មភាព | ចំនួន | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| **១.វគ្គបណ្តុះបណ្តាល** | | | | | |
| ១.១ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិត របាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ៤០០ ០០០ | ២០២៤ | ២០២៤ |
| ១.២ | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ៣០០ ០០០ | ២០២៤ | ២០២៤ |
| ១.៣ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ៤០០ ០០០ | ២០២៥ | ២០២៥ |
| ១.៤ | បណ្តុះបណ្តាលជំនាញសម្របសម្រួល | ១លើក | ២០០ ០០០ | ២០២៥ | ២០២៥ |
| ១.៥ | បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ៤០០ ០០០ | ២០២៦ | ២០២៦ |
| ១.៦ | បណ្តុះបណ្តាលរបៀបបដិសណ្ឋាកិច្ច | ១លើក | ៤០០ ០០០ | ២០២៦ | ២០២៦ |
| ១.៧ | បណ្តុះបណ្តាលពីភាពជាអ្នកដឹកនាំ | ១លើក | ៤០០ ០០០ | ២០២៦ | ២០២៦ |
| ១.៨ | ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក | ៤០០ ០០០ | ២០២៧ | ២០២៧ |
| **២.កិច្ចប្រជុំ** | | | | | |
| ២.១. | ប្រជុំផ្ទៃក្នុងរបស់គណៈកម្មការសហគមន៍ | ១២ដង | ១០០០ ០០០ | ២០២៤ | ២០២៧ |
| ២.២ | ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ | ១២ដង | | ២០២៤ | ២០២៧ |
| ២.៣ | ចូលរួមប្រជុំជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត | ៤ដង | | ២០២៤ | ២០២៧ |

### គ.១០.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍នេសាទកំពង់ត្រឡាចកំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុង និងខាងក្រៅដោយការកាប់រានព្រៃកោងកាង និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផលបានយូរអង្វែងក្នុងពេលអនាគត ចាំបាច់តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹង

គ្រប់គ្រាន់ដែលនាំដល់ការចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

ផែនការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះសកម្មភាព | អ្នកចូលរួម | រយៈពេលអនុវត្ត | | | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | | ចាប់ផ្តើម | បញ្ចប់ |
| ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | រដ្ឋបាលជលផល អ្នកពាក់ព័ន្ធ | ៤ | ៤ | ៤ | ២ ០០០ ០០០ | ២០២៤ | ២០២៧ |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | រដ្ឋបាលជលផល អ្នកពាក់ព័ន្ធ | ៤ | ៤ | ៤ | ១ ០០០ ០០០ | ២០២៤ | ២០២៧ |

### គ.១១.ផែនការបំពាក់សម្ភារៈក្នុងស្នាក់ការសហគមន៍នេសាទ

ពេលបច្ចុប្បន្ន សហគមន៍នេសាទកំពង់ត្រឡាច ត្រូវបានសង់ស្នាក់ការរួចរាល់ ប៉ុន្តែ ពុំទាន់បំពាក់សម្ភារៈនៅឡើយ ដើម្បីឱ្យគណៈកម្មការមានភាពងាយស្រួលក្នុងពេលបំពេញការងារក៏ដូចជាការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ ចាំបាច់ស្នាក់ការសហគមន៍នេសាទ ត្រូវការបំពាក់សម្ភារៈមួយចំនួនដូចជា៖ តុ កៅអី និងទូឯកសារ ដែលមានដូចខាងក្រោម៖

| ល.រ | សកម្មភាព | ទីតាំងគម្រោង | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ១ | ការបំពាក់សម្ភារៈ | ដីសហគមន៍ | ៤ ០០០ ០០០ | ២០២៤ | ២០២៧ |

### គ.១២.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍នេសាទកំពង់ត្រឡាច ត្រូវដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ក្រុមប្រឹក្សាសង្កាត់ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ។ ផែនការស្វែងរកថវិកាសម្រាប់ទ្រង់សហគមន៍មានក្នុងតារាងខាងក្រោម៖

| ល.រ | ប្រភេទចំណូល | សកម្មភាព | តម្លៃប៉ាន់ប្រមាណ (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ១ | ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ប្រជុំផ្សព្វផ្សាយ និងបណ្ណភាគទាន | ២ ០០០ ០០០ | ២០២៤ | ២០២៧ |
| ២ | ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ចេញបណ្ណ ភាគទាន | ៨ ០០០ ០០០ | ២០២៤ | ២០២៧ |
| ៣ | សប្បុរសជន និងដៃគូអភិវឌ្ឍន៍ | • បង្កើតមុខរបរ<br>• ជាថវិកាផ្ទាល់ | ៤ ០០០ ០០០ | ២០២៤ | ២០២៧ |
| ៤ | ក្រុមប្រឹក្សាសង្កាត់ | ការពារធនធានធម្មជាតិ | ១ ០០០ ០០០ | ២០២៤ | ២០២៧ |

### គ.១៣.ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដូចជា៖

• ជួយដល់គណៈកម្មការ និងសមាជិកសហគមន៍នេសាទ ដើម្បីធ្វើឱ្យប្រសើរក្នុងការគ្រប់គ្រងធនធានជលផលនិងសហគមន៍នេសាទមានការអភិវឌ្ឍន៍

• ជំរុញឱ្យអ្នកពាក់ព័ន្ធចូលរួមគាំទ្រ និងផ្តល់បច្ចេកទេសក្នុងការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព

• ឆ្លុះបញ្ចាំងពីចំនុចខ្សោយនៃដំណើរការគ្រប់គ្រងសហគមន៍នេសាទក្នុងបរិបទកំណែទម្រង់វិស័យជលផល។

ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | អ្នកចូលរួម | តម្លៃប៉ាន់ស្មាន (រៀល) | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ១ | តាមដាន និងត្រួតពិនិត្យ | គណៈកម្មការ<br>អ្នកពាក់ព័ន្ធ | ៥០០ ០០០ | ២០២៤ | ២០២៧ |
| ២ | វាយតម្លៃផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ | •អ្នកពាក់ព័ន្ធ<br>•គណៈកម្មការ | ៣ ០០០ ០០០ | | |

ឃ.យុទ្ធសាស្ត្រ

នៅក្នុងសហគមន៍នេសាទកំពង់ត្រឡាច ត្រូវរៀបចំយុទ្ធសាស្ត្រមួយចំនួន ដើម្បីឱ្យការអនុវត្តផែនការទទួលបានជោគជ័យ។ យុទ្ធសាស្ត្រទាំងមានដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃកោងកាង កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទដល់សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធសំខាន់ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទកំពង់ត្រឡាចរយៈពេល០៣ឆ្នាំ (ខែកក្កដា ឆ្នាំ២០២៤ ដល់ ខែមិថុនា ឆ្នាំ២០២៧)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| **១.ផែនការប្រើប្រាស់ឧបរណ៍នេសាទ .** | •កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>•កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>•សហគមន៍នឹងអនុវត្តន៍ប្រកាសស្តីពីការប្រើប្រាស់ឧបករណ៍ | **១ ៥០០ ០០០** | | | |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/៤ដង | •សមាជិកនឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ព័ន្ធនឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ | ១ ៥០០ ០០០ | | | |
| ១.៣.ការប្រមូលទិន្នន័យទូក | ទូកនេសាទនឹងបានបច្ចុប្បន្នភាព | | | | |
| ១.៤.ត្រួតពិនិត្យ និងតាមដាន | គណៈកម្មការ និងសមាជិកចូលរួមឃ្លាំមើល និងរាយការណ៍ | | | | |
| **២.ផែនការចុះល្បាត** | •ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់<br>•សមាជិកអាចទទួលបានផលនេសាទពីកន្លែងសហគមន៍នេសាទ<br>•គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព | **៥ ៥០០ ០០០** | | | |
| ២.១.ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ផែនការល្បាតបានពិគ្រោះយោបល់ និងរៀបចំសម្រាប់អនុវត្ត | ២០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| ២.២.រៀបចំមធ្យោបាយ និងសម្ភារៈ | មធ្យោបាយ សម្ភារៈបានគ្រោងនឹងរៀបចំ | ២ ០០០ ០០០ | | | |
| ២.៣.ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ផែនការល្បាតត្រូវបានផ្សព្វផ្សាយ | ១០០ ០០០ | | | |
| ២.៤.អនុវត្តផែនការចុះល្បាត | ផែនការចុះល្បាតត្រូវបានចុះអនុវត្ត | ៥ ០០០ ០០០ | | | |
| **៣.ផែនការកែលំអរដែននេសាទ** | •បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទ និងព្រៃកោងកាង<br>•ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ<br>•មានភ្ញៀវទេសចរណ៍និងផ្តល់ការងារដល់សហគមន៍<br>•សហគមន៍មានដើមទុនសម្រាប់ខ្លួនឯង | **២៥ ០០០ ០០០** | | | |
| ៣.១.ផែនការស្តាព្រំប្រទល់ព្រៃកនង្កលដែលមានប្រវែង២០០០មx ខ្នង២០ម បាតក្រោម ១២មxកំពស់៣ម | •ផ្សព្វផ្សាយដល់អ្នកពាកព័ន្ធទាំងអស់<br>•ធ្វើការសិក្សាលើទំហំដែលត្រូវស្តារ<br>•ការស្តារព្រៃក | **២៥ ០០០ ០០០** | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| **៤.ផែនការរៀបចំកន្លែងអភិរក្ស** | •ប្រភេទត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃកោងកាងនឹងត្រូវបានការពារ | **២៣ ០០០ ០០០** | | | |

| | | | | | |
|---|---|---|---|---|---|
| | •ប្រជាជននឹងយល់ដឹងពីសារៈសំខាន់កន្លែងអភិរក្សនឹងចូលរួមថែរក្សា | | | | |
| ៤.១.ផ្សព្វផ្សាយដល់ប្រជាជន | ប្រជាជននឹងយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | ៥ 000 000 | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| ៤.២.ធ្វើផែនទីកន្លែងអភិរក្សសហគមន៍ | ផែនទីកន្លែងអភិរក្សសហគមន៍នឹងត្រូវបានធ្វើ | ១ 000 000 | | | |
| ៤.៣.បោះបង្គោលស៊ីម៉ង់ចំនួន២០ដើម | ចំនួន២០បង្គោលនឹងបានបោះព្រំប្រទល់សហគមន៍ | ៥ 000 000 | | | |
| ៤.៤.បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្ស១៥ដើម | ចំនួន១០បង្គោលនឹងបានបោះនៅកន្លែងអភិរក្ស ដោយមានផែនទីសំគាល់ | ៣ 000 000 | | | |
| ៤.៥.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ និងស្លាកតូច | ចំនួន០៤ផ្ទាំងប៉ាណូ និងស្លាកតូចចំនួន៦០ នឹងបោះសម្រាប់ផ្សព្វផ្សាយ | ៥ 000 000 | | | |
| ៤.៦.សង់រោងយាម | រោងយាមចំនួន០១ត្រូវបានសាងសងនៅកន្លែងអភិរក្សទំហំ៤ម×៥ម | ៣ 000 000 | | | |
| ៤.៧.ចុះល្បាតជាប្រចាំ | បទល្មើសនេសាទនឹងថយចុះតាមរយៈការចុះល្បាត | ១ 000 000 | | | |
| **៥.ផែនការគ្រប់គ្រងព្រៃកោងកាងទំហំ១៩ហិកតា** | •សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃព្រៃកោងកាង<br>•ព្រៃកោងកាងត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | **៤ 000 000** | | | |
| ៥.១.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃកោងកាង | សមាជិកសហគមន៍យល់ដឹងពីសារៈប្រយោជន៍ព្រៃកោងកាង | ២00 000 | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២៤ | ២០២៧ |
| ៥.២.ដាំព្រៃកោងកាង | ទំហំដីចំនួន៣ហិកតា នឹងដាំកូនឈើកោងកាង និងដាក់ស្លាកសញ្ញាការពារ | ២ 000 000 | | | |
| ៥.៣.ថែរក្សា និងការពារព្រៃកោងកាងទំហ៦៦ហិកតា | ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់ និងដាក់ស្លាកសញ្ញាការពារ | ៨00 000 | | | |
| ៥.៤.ចុះល្បាតជាប្រចាំ | សកម្មភាពកាប់បំផ្លាញព្រៃកោងកាងនឹងត្រូវបានទប់ស្កាត់ | ១ 000 000 | | | |
| **៦.ការអភិវឌ្ឍន៍វារីវប្បកម្ម** | •បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>•រកប្រាក់ចំណូលជួយស្តួយសេដ្ឋកិច្ចគ្រួសារ<br>•កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហួសកំរិត | **២៣ 000 000** | | | |
| **៦.១.ចិញ្ចឹមត្រីឆ្តងលក្ខណៈគ្រួសារចំនួន២០គ្រួសារ** | | **៥ 000.000** | | | |
| ៦.១.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន២០គ្រួសារត្រូវបានជ្រើសរើស | ៥ 000 000 | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| ៦.១.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | ចំនួន២០គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តង | | | | |
| ៦.១.៣.ធ្វើបែចិញ្ចឹមត្រីឆ្តង | ចំនួន២០បែដែលក្នុង១បែមានទំហំ៥ម×៣ម×២,៥ម ត្រូវបានសាងសង់ | | | | |
| ៦.១.៤.ការដាក់កូនត្រីក្នុងបែ | ចំនួនកូនត្រី៥០០ក្បាល នឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |
| ៦.១.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន២០គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៦.២.ចិញ្ចឹមត្រីគក់កែលក្ខណៈគ្រួសារចំនួន៦គ្រួសារ** | | **៧ 000 000** | | | |
| ៦.២.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន៦គ្រួសារត្រូវបានជ្រើសរើស | ៧ 000 000 | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| ៦.២.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីគុកកែ | ចំនួន៦គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីគុកកែ | | | | |
| ៦.២.៣ ធ្វើបែចិញ្ចឹមត្រីគុកកែ | ចំនួន៦បែដែលក្នុង១បែមានទំហំ៥ម×៣ម×២,៥មត្រូវបានសាងសង់ | | | | |
| ៦.២.៤.ការដាក់កូនត្រីក្នុងបែ | ចំនួនកូនត្រី៥០០កូននឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៦.២.៥.ត្រួតពិនិត្យ និងតាមដាន | សមាជិកសហគមន៍ចំនួន៦គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៦.៣.ចិញ្ចឹមអយស្ទ័របង្គុំចំពុះទាចំនួន១០គ្រួសារ** | **សមាជិកសហគមន៍ចំនួន១០គ្រួសារនឹងចិញ្ចឹមអយស្ទ័របង្គុំចំពុះទា** | **៣ ០០០ ០០០** | | | |
| ៦.៣.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន១០គ្រួសារត្រូវបានជ្រើសរើស | ៣ ០០០ ០០០ | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| ៦.៣.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | ចំនួន១០គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | | | | |
| ៦.៣.៣.សាងសង់កន្លែងចិញ្ចឹមអយស្ទ័របង្គុំចំពុះទា | កន្លែងចិញ្ចឹមអយស្ទ័របង្គុំចំពុះទានឹងត្រូវសង់ | | | | |
| ៦.៣.៤.ការដាក់កូនអយស្ទ័របង្គុំចំពុះទានៅកន្លែងចិញ្ចឹម | កូនអយស្ទ័របង្គុំចំពុះទានឹងត្រូវបានផ្តល់ក្នុងគ្រួសារនីមួយៗ | | | | |
| ៦.៣.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន១០គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៦.៤.ចិញ្ចឹមក្តាមថ្មលក្ខណៈគ្រួសារចំនួន១០គ្រួសារ** | សមាជិកសហគមន៍ចំនួន១០គ្រួសារនឹងចិញ្ចឹមអយស្ទ័របង្គុំចំពុះទា | **៤ ០០០ ០០០** | | | |
| ៦.៤.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន១០គ្រួសារត្រូវបានជ្រើសរើស | ៤ ០០០ ០០០ | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| ៦.៤.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | ចំនួន១០គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | | | | |
| ៦.៤.៣ ធ្វើកន្លែងចិញ្ចឹមក្តាមថ្ម | នឹងធ្វើកន្លែងចិញ្ចឹមក្តាមថ្ម | | | | |
| ៦.៤.៤.ដាក់ក្តាមថ្ម | ក្តាមថ្មនឹងត្រូវបានផ្តល់ក្នុងគ្រួសារនីមួយៗ | | | | |
| ៦.៤.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន១០គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៦.៥.រៀបចំធាគារក្តាមសេះចំនួន១៥គ្រួសារ** | | **៤ ០០០ ០០០** | | | |
| ៦.៥.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន១៥គ្រួសារត្រូវបានជ្រើសរើស | ៤ ០០០ ០០០ | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| ៦.៥.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | ចំនួន១៥គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | | | | |
| ៦.៥.៣ សង់បែចិញ្ចឹម | នឹងសង់បែចិញ្ចឹម | | | | |
| ៦.៥.៤.ដាក់មេក្តាមសេះ | មេក្តាមសេះនឹងត្រូវបានផ្តល់ | | | | |
| ៦.៥.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន១៥គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៧.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព** | | **៤ ៥០០ ០០០** | | | |
| **៧.១.ការចិញ្ចឹមមាន់លក្ខណៈគ្រួសារចំនួន០៧គ្រួសារ** | **ចំនួន០៧គ្រួសារ នឹងចិញ្ចឹមមាន់លក្ខណៈគ្រួសារ** | **១ ៥០០ ០០០** | | | |
| ៧.១.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន០៥គ្រួសារត្រូវបានជ្រើសរើស | ១ ៥០០ ០០០ | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | ២០២៤ | ២០២៧ |
| ៧.១.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | ចំនួន០៧គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | | | | |
| ៧.១.៣ ធ្វើទ្រុងចិញ្ចឹម | នឹងធ្វើទ្រុងចិញ្ចឹម | | | | |
| ៧.១.៤.ផ្តល់សម្ភារៈ និងពូជ | សម្ភារៈនិងពូជនឹងត្រូវបានផ្តល់ក្នុងគ្រួសារនីមួយៗ | | | | |
| ៧.១.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន០៧គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |

| | | | | | |
|---|---|---|---|---|---|
| **៧.២.ការកែច្នៃផ្ទកលក្ខណ:គ្រួសារចំនួន៥គ្រួសារ** | **ចំនួន៥គ្រួសារនឹងត្រូវបានជ្រើសរើសសម្រាប់ការកែច្នៃផ្អក** | **១ ៥០០ ០០០** | | | |
| ៧.២.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន០៥គ្រួសារត្រូវបានជ្រើសរើស | | | | |
| ៧.២.២.បណ្តុះបណ្តាលបច្ចេកទេសកែច្នៃផ្អក | ចំនួន០៥គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសកែច្នៃផ្អក | | | | |
| ៧.២.៣ ធ្វើកន្លែងកែច្នៃផ្អក | នឹងធ្វើកន្លែងកែច្នៃផ្អក | | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | | |
| ៧.២.៤.ផ្តល់សម្ភារ: | សម្ភារ:នឹងត្រូវបានផ្តល់ក្នុងគ្រួសារនីមួយៗ | ១ ៥០០ ០០០ | | ២០២៤ | ២០២៧ |
| ៧.២.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន០៥គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៧.៣.ការកែច្នៃគីលក្ខណ:គ្រួសារចំនួន៥គ្រួសារ** | | **១ ៥០០ ០០០** | | | |
| ៧.៣.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន០៥គ្រួសារត្រូវបានជ្រើសរើស | | | | |
| ៧.៣.២.បណ្តុះបណ្តាលបច្ចេកទេសកែច្នៃ | ចំនួន០៥គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសកែច្នៃ | | | | |
| ៧.៣.៣ ធ្វើកន្លែងកែច្នៃគី | នឹងធ្វើកន្លែងកែច្នៃគី | | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | | |
| ៧.៣.៤.ផ្តល់សម្ភារ: | សម្ភារ:នឹងត្រូវបានផ្តល់ក្នុងគ្រួសារនីមួយៗ | ១ ៥០០ ០០០ | | ២០២៤ | ២០២៧ |
| ៧.៣.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន០៥គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍** | | **២៥ ០០០ ០០០** | | | |
| ៨.១.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | នឹងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | | | | |
| ៨.២.រៀបចំក្រុមសម្រាប់កន្លែងកំសាន្ត | នឹងរៀបចំក្រុមសម្រាប់កន្លែងកំសាន្ត | | | | |
| ៨.៣.បង្កើតគោលការណ៍ | នឹងបង្កើតគោលការណ៍ | | | | |
| ៨.៤.បណ្តុះបណ្តាល | នឹងបណ្តុះបណ្តាល | | | | |
| ៨.៥.ធ្វើកញ្ចុះ ផ្ទះលំហែ ផ្ទះបាយ និងបន្ទប់ទឹក | នឹងធ្វើកញ្ចុះ ផ្ទះលំហែ ផ្ទះបាយ និងបន្ទប់ទឹក | | | | |
| ៨.៦.សង់ស្ពានមួយខ្សែ និងផ្លូវមួយខ្សែ | នឹងសង់ស្ពានមួយខ្សែ និងផ្លូវមួយខ្សែ | | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | | |
| ៨.៧.ធ្វើចំណតយានយន្ត កន្លែងគ្រប់គ្រងកាកសំណល់ | នឹងធ្វើចំណតយានយន្ត និងកន្លែងគ្រប់គ្រងកាកសំណល់ | ២៥ ០០០ ០០០ | | ២០២៤ | ២០២៧ |
| ៨.៨.សង់សួនថតអនុស្សាវរី | នឹងសង់សួនថតអនុស្សាវរី | | | | |
| ៨.៩.បំពាក់សម្ភារ: ភ្លើង និងទឹក | នឹងបំពាក់សម្ភារ: ភ្លើង និងទឹក | | | | |
| **៩.ការពង្រឹងសមត្ថភាពគណ:កម្មការសហគមន៍នេសាទ** | •គណ:កម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>•យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់និង<br>•បង្កើនសាមគ្គីភាព និងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | **៣ ៩០០ ០០០** | | | |
| **៩.១.ការរៀបចំវគ្គបណ្តុះបណ្តាល** | | **២ ៦០០ ០០០** | | | |
| ៩.១.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍និងលិខិតរដ្ឋបាល | កំណត់ហេតុ សរសេររបាយការណ៍និងលិខិតរដ្ឋបាលនឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៤ | ២០២៤ |

| | | | | | |
|---|---|---|---|---|---|
| ៩.១.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកានឹងត្រូវបានបណ្តុះបណ្តាល | ៣០០ ០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២៥ | ២០២៥ |
| ៩.១.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៥ | ២០២៥ |
| ៩.១.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០ ០០០ | | ២០២៥ | ២០២៥ |
| ៩.១.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៦ | ២០២៦ |
| ៩.១.៦.បណ្តុះបណ្តាលរបៀបបដិសណ្ឋាកិច្ច | របៀបបដិសណ្ឋាកិច្ចនឹងបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៦ | ២០២៦ |
| ៩.១.៧.បណ្តុះបណ្តាលពីភាពជាអ្នកដឹកនាំ | ភាពជាអ្នកដឹកនាំនឹងបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៦ | ២០២៦ |
| ៩.១.៨.ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | ៤០០ ០០០ | | ២០២៧ | ២០២៧ |
| **៩.២.កិច្ចប្រជុំ** | | **១ ០០០ ០០០** | | | |
| ៩.២.១.ប្រជុំផ្ទៃក្នុងរបស់គណៈកម្មការសហគមន៍ | គណៈកម្មការសហគមន៍នឹងរៀបចំប្រជុំផ្ទៃក្នុងមួយខែមួយម្តង | ១ ០០០ ០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២៦ | ២០២៦ |
| ៩.២.២.ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ | នឹងចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំក្នុងមួយខែមួយម្តង | | | | |
| ៩.២.៣.ចូលរួមប្រជុំជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត | នឹងចូលរួមប្រជុំជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត | | | | |
| **១០.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ និងកសាងសមត្ថភាពគណៈកម្មការ** | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | **២ ០០០ ០០០** | | | |
| ១០.១.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | សមាជិកសហគមន៍នឹងផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋាន | ២ ០០០ ០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២៤ | ២០២៧ |
| ១០.២.ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | សមាជិកសហគមន៍នឹងត្រូវបានផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | ១ ០០០ ០០០ | | | |
| **១១.ផែនការបំពាក់សម្ភារៈស្នាក់ការសហគមន៍នេសាទ** | | **៤ ០០០ ០០០** | | | |
| ១១.១.បំពាក់សម្ភារៈ | សម្ភារៈកៅអី និងទូឯកសានឹងត្រូវបានបំពាក់ | ៤ ០០០ ០០០ | | ២០២៤ | ២០២៧ |
| **១២.ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ** | | **១៥ ០០០ ០០០** | | | |
| ១២.១.ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ២ ០០០ ០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២៤ | ២០២៧ |
| ១២.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ៨ ០០០ ០០០ | | | |
| ១២.៣.អំណោយពីសប្បុរសជននិងអង្គការដៃគូ | សប្បុរសជននិងអង្គការដៃគូអភិវឌ្ឍន៍ | ៤ ០០០ ០០០ | | | |
| ១២.៤.ក្រុមប្រឹក្សាសង្កាត់ | មូលនិធិរបស់សង្កាត់ | ១ ០០០ ០០០ | | | |
| **១៣.ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | | **៣ ៥០០ ០០០** | | | |
| ១៣.១.តាមដាន និងត្រួតពិនិត្យជាប្រចាំ | ការអនុវត្តសកម្មភាពរបស់សហគមន៍នឹងធ្វើការតាមដាន និងត្រួតពិនិត្យជាប្រចាំ | ៥០០ ០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២៤ | ២០២៧ |
| ១៣.២.វាយតម្លៃផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ | នឹងធ្វើការវាយតម្លៃផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ | ៣ ០០០ ០០០ | | | |

# តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទកំពង់ត្រឡាចក្នុងរយៈពេល០៣ឆ្នាំ

| សកម្មភាព | ២០២៤ | | | | | | | | ២០២៥ | | | | | | | | | | | | ២០២៦ | | | | | | | | | | | | ២០២៧ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែនីមួយៗ | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | |
| | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 |
| ១.ផែនការប្រើប្រាស់ឧបណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.ផែនការចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.ផែនការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.ផែនការរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.ផែនការគ្រប់គ្រងព្រៃកោងកាង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.ការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១១.ផែនការបំពាក់សម្ភារៈស្នាក់ការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១២.ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១៣.ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

សូមគោរពជូន

លោកចៅសង្កាត់ព្រៃធំ

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កំពង់ត្រឡាច ថ្ងៃទី២៧ ខែ........ ឆ្នាំ២០២៤

**ប្រធាន**

**គណៈកម្មការសហគមន៍នេសាទកំពង់ត្រឡាច**

លេខ: ០៣៨ ...

បានឃើញ និងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកែប

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃ........ ខែ........ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កែប ថ្ងៃទី១៧ ខែ........ ឆ្នាំ ២០២៤

**នាយខណ្ឌរដ្ឋបាលជលផលកែប**

**គុជ ទិរៈ**

លេខ: ...

បានឃើញ និងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលដំណាក់ស្ដេច

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃ........ ខែ........ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ព្រៃធំ ថ្ងៃទី........ ខែ........ ឆ្នាំ២០២៤

**ចៅសង្កាត់**

**គួច_សាម៉ន**

លេខ ១៤៧ ...

បានឃើញ និងគោរពជូន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

ដើម្បីពិនិត្យ និងសម្រេចដោយអនុគ្រោះ

ថ្ងៃ........ ខែ........ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កែប ថ្ងៃទី ១៧ ខែ........ ឆ្នាំ ២០២៤

**ប្រធាន**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកែប**

**ធីង_បូរិន**

លេខ ...

បានឃើញ និងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកែប

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃ........ ខែ........ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ដំណាក់ស្ដេច ថ្ងៃទី........ ខែ........ ឆ្នាំ២០២៤

**នាយផ្នែករដ្ឋបាលជលផលដំណាក់ស្ដេច**

លេខ ១១៥១ ...

បានឃើញ និងឯកភាព

ថ្ងៃ........ ខែ........ ឆ្នាំ........

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ........ ឆ្នាំ២០២៤

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**ពុំ សុថា**